**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងរវាងនាយិកាក្រុមហ៊ុនចាន់រីទ្រីនិងតំណាងកម្មករនិយោជិក ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី១០ខែមករា ឆ្នាំ២០២២ វេលាម៉ោង ៩ និង ៣០នាទី នៅក្នុងក្រុមហ៊ុនភោជនីយដ្ឋានចាន់រីទ្រីមានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិក។

នៅក្នុងអង្គប្រជុំនេះនាយិកាក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិកទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរបស់ក្រុមហ៊ុនថា ដោយសារការរីករាលដាលនិងចម្លងនៃជំងឺរលាកសួតប្រភេទថ្មីCovid-19ដែលជាហេតុបណ្តាលអោយមានផលប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោកហើយក៏ជាហេតុដែលធ្វើអោយក្រុមហ៊ុនទទួលរងការខាតបង់ មិនមានប្រាក់ចំណូលសំរាប់ទ្រទ្រង់ប្រតិបត្តិការណ៍បន្តទៀតបាន។

ហេតុដូចនេះក្រុមហ៊ុនបានសំរេចចិត្តធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិកទាំងអស់ចំនួន ៦០នាក់ (ស្រី១៣នាក់)រយៈពេល៦០ថ្ងៃដោយគិតចាប់ពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ រហូតដល់ទី២៥ ខែមិនា ឆ្នាំ២០២២ នៅក្នុងកំឡុងពេលនៃការព្យួរនេះកម្មករនិយោជិកនឹងមិនទទួលបានអត្ថប្រយោជន៍អ្វីពីក្រុមហ៊ុនឡើយ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១០និង៣០នាទីនាថ្ងៃខែឆ្នាំដដែលដោយសារភាគីទាំងសងខាងមានការស្និទ្ធស្នាលនិងយោគយល់គ្នាក្រោមស្មារតីទទួលនិងសហការគ្នាយ៉ាងរលូន។

ថ្ងៃច័ន្ទ៨កើតខែមិកសិរឆ្នាំឆ្លូវត្រីស័កព.ស២៥៦៥
សៀមរាប ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២

ហត្ថលេខា និងត្រា នាយិកា

ព្រះរាជាណាចក្រកម្ពុជា
ចន្ទ្រី ទ្រី
CHANREY TREE
KINGDOM OF CAMBODIA

ជុនតាប់

តំណាងកម្មករនិយោជិក